ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៧៥/០៩-អាប្ជាធរអប្សរា

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : អាជ្ញាធរអប្សរា

អាសយដ្ឋាន : ភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ : ០១២ ៧៦១ ៧១៧ ទូរសារ : ០២៣ ៩៦៩ ៧៥៧

តំណាងភាគីនិយោជកៈ

១- លោក ឈិត បូរ៉ារុធ មេធាវីអាជ្ញាធរអប្សរា

២- លោក ពេជ្រ សូរិយា មេធាវីអាជ្ញាធរអប្សរា

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

- សហជីពកម្មករអភិរក្សទឹក និងព្រៃឈើ នៃអាជ្ញាធរអប្សរា (WFCUA)

អាសយដ្ឋាន : ភូមិវាល ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប

លេខទូរស័ព្ទ : ០១២ ៧៥២ ៦១៧ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោក សុខ សុវណ្ណដេត ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- លោក វ៉ាន់ ថុល អនុប្រធានសហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា

៣- លោក ប្រេង បាន ប្រធានសហជីពប្រចាំរោងចក្ររអប្សរា

៤- លោក យ៉ាន់ ធី បុគ្គលិកសហព័ន្ធសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យឈប់សម្រាកថ្ងៃបុណ្យមានប្រាក់ឈ្នួល។

២- កម្មករនិយោជិតទាមទារឱ្យទទួលយកកម្មករចំនួន ១៤ នាក់ ចូលធ្វើការវិញ។

៣- ការទាមទារឱ្យស្ត្រីមានផ្ទៃពោះឈប់សម្រាករយៈពេល ៣ ខែ ដោយរក្សាប្រាក់ឈ្នួលហាសិបភាគរយ។

៤- ការទាមទារឱ្យមានប្រាក់ឧបត្ថម្ភពេលកម្មករមានជំងឺ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៩៥៦ កប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១០ (វេលាម៉ោង ០៨:០០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតទាមទារឱ្យលោក សាខុន ប៊ូរិន ទទួលយកកម្មករនិយោជិតចំនួន ២៩ នាក់ ចូលធ្វើការវិញ និងកែលំអរលក្ខខណ្ឌការងារឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៧ លើការទាមទារចំនួន ០៤ ចំណុច ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ ត្រូវបានបញ្ជូនមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ តាមរបាយការណ៍ស្តីពីវិវាទការងាររួម មិនសះជាលេខ ១១៦២ ម.ក.ប ចុះថ្ងៃ ទី០៩ ខែធ្នូ ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញ ភាគីអាជ្ញាធរអប្សរា និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។ ប៉ុន្តែ លោកមេធាវីតំណាង ដោយអាណត្តិឱ្យអាជ្ញាធរអប្សរា បានដាក់ពាក្យសុំពន្យារពេលសវនាការ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ដើម្បីឱ្យ មានពេលវេលាគ្រប់គ្រាន់សិក្សាទៅលើសំណុំរឿងនេះ។ ដោយមានការព្រមព្រៀងពីភាគីកម្មករនិយោជិត ក្រុម ប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃសវនាការសារជាថ្មី នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ៨:០០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមាន នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន ព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជា ទាំង ០៤ ចំណុចនេះបន្ថែមទៀត ដោយភាគីកម្មករនិយោជិតបានសម្រេចដកចេញនូវចំណុចវិវាទទី៣ និងទី៤ ចេញ ពីការទាមទារ។ ដូច្នេះ ចំណុចវិវាទដែលនៅសល់គឺ ចំណុចវិវាទទី១ និងទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការ ពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោមៈ

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៈ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៈ

១- ពាក្យសុំពន្យាពេលសវនាការរបស់លោកមេធាវី ឈិត បូរ៉ាវុធ ជាមេធាវីតំណាងដោយអាណត្តិ ឱ្យ អាជ្ញាធរអប្សរា ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការសុំពន្យាពេលសវនាករ លើសំណុំរឿងវិវាទការងារ លេខ ១៧៥/០៩ និង លេខ ១៧៦/០៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតផ្ទេរសិទ្ធិតំណាងដោយអាណត្តិ របស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ប្រគល់សិទ្ធិជូនលោកមេធាវី ឈិត បូរ៉ាវុធ លេខ ៦១០/០៩ រប.លប្រស ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩។

៣- លិខិតផ្ទេរសិទ្ធិតំណាងដោយអាណត្តិរបស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ប្រគល់សិទ្ធិជូនលោកមេធាវី ពេជ្រ សូរិយា លេខ ០៣៧/១០ រប.លប្រស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

៤- សេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៦៨ សសរ ស្តីពីការតែងតាំងក្រុមការងារច្បាប់ជួយអាជ្ញាធរអប្សរា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សារណាវិវាទការងារទាក់ទងនឹងវិវាទការងាររវាងកម្មករនិយោជិត និងអាជ្ញាធរអប្សរា លើសំណុំរឿងលេខ ១៧៥/០៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករអភិរក្សទឹក និងព្រៃឈើនៃអាជ្ញាធរអប្សរា (WFCUA) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០។

៤- បញ្ជីរាយឈ្មោះថ្នាក់ដឹកនាំ និងសមាជិកសហជីពដែលត្រូវបានបញ្ឈប់ពីការងារ។

៥- ឯកសាររូបភាពមួយចំនួន។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- លិខិតលេខ ១៥៥៦ កប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំដោះស្រាយវិវាទការងាររួមនៅអាជ្ញាធរអប្សរា។

២- លិខិតលេខ ១១៦២ មកប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីរបាយការណ៍ដោះស្រាយវិវាទការងាររួមនៅអាជ្ញាធរអប្សរា។

៣- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់អាជ្ញាធរអប្សរា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ ២០០៧។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីអាជ្ញាធរអប្សរាជ្រើសរើសក្រុមអាជ្ញាកណ្តាលលេខ ៦១៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសមាគមអាជ្ញាធរអប្សរា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩។

៣- លិខិតអញ្ជើញភាគីអាជ្ញាធរអប្សរាចូលរួមសវនាការលើកទី១ លេខ ៩២៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៩២៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩។

៥- លិខិតអញ្ជើញភាគីអាជ្ញាធរអប្សរាចូលរួមសវនាការលើកទី២ លេខ ០១៨ កប/អក/វក/លកអ. ចុះថ្ងៃ ទី០៨ ខែមករា ឆ្នាំ២០១០។

THE ARBITRATION COUNCIL

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ០១៩ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- អាជ្ញាធរអប្សរា បានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ មានបុគ្គលិកបំរើការងារពីរប្រភេទ គឺបុគ្គលិកជាមន្ត្រីរាជការ និងកម្មករនិយោជិត (បុគ្គលិក) ជាប់កិច្ចសន្យា ព្រមទាំងកម្មករនិយោជិតដែលធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ។ ក្នុងនោះ មានកម្មករនិយោជិតដែលធ្វើ ការយកប្រាក់ឈ្នួលប្រចាំថ្ងៃចំនួន ១៤ នាក់ និងសហព័ន្ធសហជីព កម្មករសំណង់ និងព្រៃឈើកម្ពុជា ដែលមានសហជីពកម្មករអភិរក្សទឹក និងព្រៃឈើនៃអាជ្ញាធរ អប្សរា (WFCUA) ជាសមាជិកសហព័ន្ធ គឺជាភាគីដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ។
- ភាគីសហជីពបានបញ្ជាក់ថា កម្មករនិយោជិត ទាំង ១៤ នាក់នេះ ជាថ្នាក់ដឹកនាំ និងជាសមាជិក សហជីព។ សហជីពបានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកា លេខ ១០៧៣ ក.ក.ប.វ/វក. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ ដែលមានលោក ប្រេង បាន ជាប្រធាន លោក យ៉ាន មុល ជាអនុប្រធាន និងលោក មាន ជា ជាលេខាធិការ។ សព្វថ្ងៃនេះ អាជ្ញាធរអប្សរាបានទទួលយកលោក មាន ជា ឱ្យចូលធ្វើការ វិញហើយ ពីព្រោះ លោក មាន ជា បានលាឈប់ពីតំណែងជាលេខាសហជីពហើយ។ ដូច្នេះ មក ដល់ថ្ងៃសវនាការនេះ កម្មករនិយោជិត ដែលធ្វើការទាមទារនៅក្នុងសំណុំរឿងនេះ មានតែ ១៣ នាក់ ទេ។ ក្រុមប្រឹក្សា អាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីសហជីព រៀបចំបញ្ជីឈ្មោះកម្មករនិយោជិតដែល នៅធ្វើការទាមទារ ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ពីព្រោះបណ្តឹង ទាមទារនេះបានកើតឡើងតាំងពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ មកម្លេះ។ ប៉ុន្តែ រហូតដល់កាល បរិច្ឆេទកំណត់នេះ ភាគីសហជីពបានផ្តល់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចដែលមានក្នុងបញ្ជីឈ្មោះ និងផ្តិតស្នាមមេដៃ គឺមានតែ ៣ នាក់ ប៉ុណ្ណោះ គឺ លោក ប្រេង បាន លោក យ៉ាន មុល និងលោកស្រី ញិប សុគុំ។

**ចំណុចវិវាទទី១៖ ភាគីកម្មករនិយោជិតទាមទារឱ្យអាជ្ញាធរអប្សរា សងប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កន្លងមក អាជ្ញាធរអប្សរា មិនដែលផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅថ្ងៃបុណ្យដែលមានប្រាក់ឈ្នួលទេ។ ហេតុនេះ ពួកគាត់ទាមទារឱ្យអាជ្ញាធរអប្សរាសងប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលឡើងវិញ។
- លោក ឈិត ប៊ូរ៉ាវុធ ជាមេធាវីតំណាងដោយអាណត្តិឱ្យអាជ្ញាធរអប្សរា បានបញ្ជាក់ថា អាជ្ញាធរអប្សរាមានកម្មករជាប់លាប់ និងកម្មករធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ ដូចជា កម្មករបោសសំអាត កម្មករកាប់ឆ្ការព្រៃ ស្របតាមតម្រូវការគម្រោងនីមួយៗ ជាដើម (ក្នុងមួយថ្ងៃទទួលបានប្រាក់ឈ្នួលពី ៦០០០ រៀល ឬ ៧០០០ រៀល ទៅ ៨០០០ រៀល)។ ចំពោះកម្មករជាប់លាប់ ធ្វើការចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ទទួលបានប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលពីអាជ្ញាធរអប្សរា។ ដោយឡែក ចំពោះកម្មករធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ គឺធ្វើការមិនជាប់លាប់ទេ គឺពេលខ្លះធ្វើការតែ ៣ ថ្ងៃ ឬ ៤ ថ្ងៃ ក្នុងមួយសប្តាហ៍ ក៏មានដែរ អាស្រ័យទៅតាមតម្រូវការគម្រោងនីមួយៗ ពីព្រោះអាជ្ញាធរអប្សរាមាន គម្រោងច្រើន។ បើកម្មករនិយោជិតណាមិនអាចមកធ្វើការបានទេ ពួកគេអាចឱ្យបងប្អូន ប្តី ឬ ប្រពន្ធ មកធ្វើការជំនួសបាន ហើយអាជ្ញាអប្សរាមិនបានផ្តល់ប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលទេ ពីព្រោះអាជ្ញាធរអប្សរាយល់ឃើញថា ពួកគាត់ជាកម្មករម្តងម្កាល មិនមែនជាកម្មករជាប់លាប់ទេ។
- ភាគីកម្មករនិយោជិតមិនជំទាស់ទៅនឹងការលើកឡើងរបស់លោកមេធាវីទេ។ ប៉ុន្តែ ពួកគាត់សុំឱ្យអាជ្ញាធរអប្សរា ផ្តល់ប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ជូនពួកគាត់ដែលធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃនេះ ដូចកម្មករជាប់លាប់ដែរ។
- ភាគីកម្មករនិយោជិត និងភាគីអាជ្ញាធរអប្សរា បានទទួលស្គាល់ថា កម្មករធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃនេះ គឺពួកគាត់មានកិច្ចសន្យាផ្ទាល់មាត់។
- ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា កម្មករធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ (ក្នុងមួយថ្ងៃទទួលបានប្រាក់ឈ្នួលពី ៦០០០ រៀល ឬ ៧០០០ រៀល ទៅ ៨០០០ រៀល) មែន។ ប៉ុន្តែ ពួកគាត់បើកប្រាក់ឈ្នួលនេះ ជាប្រចាំខែ គឺនៅថ្ងៃទី៥ ឬ ទី៦ នៃខែ។ លោកមេធាវី មិនជំទាស់ទៅនឹងការលើកឡើងនេះទេ ប៉ុន្តែ លោកមេធាវី នៅប្រកាន់ជំហរថា ពួកគាត់មិនមែនជាកម្មករជាប់លាប់ទេ គឺពួកគាត់ជាកម្មករម្តងម្កាល។

**ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យអាជ្ញាធរអប្សរាទទួលយកលោក ប្រេង បាន លោក យ៉ាន មុល និង លោកស្រី ញិប សុគុំ ចូលធ្វើការវិញ**

- លោក **ប្រេង បាន** បានចូលធ្វើការនៅចុងឆ្នាំ២០០៥ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនបានដឹងពីថ្ងៃចូលធ្វើការរបស់ លោក **យ៉ាន មុល** និង លោកស្រី **ញិប សុគុំ** ទេ គ្រាន់តែដឹងថា ពួកគាត់ត្រូវបានបញ្ឈប់នៅថ្ងៃជាមួយគ្នា ហើយពួកគាត់ទាំងអស់មានកិច្ចសន្យាផ្ទាល់មាត់។
- ភាគីកម្មករនិយោជិតបានបញ្ជាក់នៅក្នុងសវនាការថា អាជ្ញាធរអប្សរា បញ្ឈប់ពួកគាត់ពីការងារដោយសារការរើសអើងសហជីព ពីព្រោះលោក សាខុន ប៊ូរិន ដែលជាអ្នកគ្រប់គ្រង ធ្លាប់បានហៅកម្មករនិយោជិតទៅការិយាល័យ ឱ្យពួកគាត់ដកខ្លួនចេញពីសហជីព ដោយបាននិយាយថា បើសិនជាកម្មករនិយោជិតចង់បានការងារនេះធ្វើតទៅទៀត ត្រូវលាលែងពីសហជីព។ បន្ទាប់មក នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ អាជ្ញាធរអប្សរា បានបញ្ឈប់ពួកគាត់ពីការងារ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមទៀតថា អាជ្ញាធរអប្សរា បានបញ្ឈប់កម្មករនិយោជិតដែលជាថ្នាក់ដឹកនាំ និងជាសមាជិកសហជីព។ ប៉ុន្តែ បើកម្មករនិយោជិតណា លាលែងពីសហជីព អាជ្ញាធរអប្សរា នឹងទទួលយកចូលធ្វើការវិញ។ ជាក់ស្តែង លោក មាន ជា ជាលេខាសហជីព ដែលបានលាឈប់ពីសហជីព ត្រូវបានអាជ្ញាធរអប្សរាទទួលយកចូលធ្វើការវិញ។ ហេតុនេះ ភាគីកម្មករនិយោជិតនៅតែចោទថា អាជ្ញាធរអប្សរា មានការរើសអើងសហជីព។
- លោកមេធាវីតំណាងភាគីអាជ្ញាធរអប្សរាបានបញ្ជាក់ថា សព្វថ្ងៃនេះ លោក សាខុន ប៊ូរិន បានលាឈប់ពីការងាររួចហើយ ហើយអាជ្ញាធរអប្សរាមិនមានការរើសអើងសហជីពទេ។ បើសិនជាមានការរើសអើងសហជីពនោះ អាជ្ញាធរអប្សរាមិនអនុញ្ញាតឱ្យមានការចុះបញ្ជិកាសហជីពនោះទេ។ លោកមេធាវីមិនបានផ្តល់អង្គហេតុ និងអំណះអំណាង ឆ្លើយតបទៅនឹងការលើកឡើងរបស់កម្មករនិយោជិតទេ គឺគ្រាន់តែឆ្លើយតបថា អាជ្ញាធរអប្សរាមិនមានការរើសអើងសហជីពទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអនុញ្ញាតឱ្យលោកមេធាវីធ្វើលិខិតជំទាស់ទៅនឹងឯកសារ ភស្តុតាងនានាក៏ដូចជាសារណាសង្ខេបរបស់ភាគីកម្មករនិយោជិត ដែលបានដាក់ជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅត្រឹមថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០។ ប៉ុន្តែ រហូតដល់កាលបរិច្ឆេទកំណត់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនទទួលបានលិខិតជំទាស់ពីលោកមេធាវីនោះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ កម្មករនិយោជិត ដែលជាថ្នាក់ដឹកនាំសហជីពត្រូវបានបញ្ឈប់ពីការងារ គឺអាជ្ញាធរអប្សរា ពុំបានធ្វើលិខិតស្នើសុំការអនុញ្ញាតពីអធិការកិច្ចនោះទេ។

## ហេតុផលនៃសេចក្តីសម្រេចៈ

នៅក្នុងរបាយការណ៍នៃកំណត់ហេតុមិនសះជា ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតដែលទាមទារក្នុងសំណុំរឿងនេះ មានចំនួន ១៣ នាក់ ជាថ្នាក់ដឹកនាំ និងជាសមាជិកសហជីព។ ប៉ុន្តែ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតដែលធ្វើការទាមទារពិតប្រាកដនៅក្នុងសំណុំរឿងនេះ មានចំនួនតែ បី នាក់ប៉ុណ្ណោះ គឺ លោក **ប្រេង បាន** លោក **យ៉ាន មុល** និងលោកស្រី **ញិប សុគុំ**។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាការទាមទារនៅក្នុងសំណុំរឿងនេះ សម្រាប់តែកម្មករនិយោជិត បីនាក់ ដែលបានធ្វើការទាមទារតែប៉ុណ្ណោះ។

**ចំណុចវិវាទទី១: ភាគីកម្មករនិយោជិតទាមទារឱ្យអាជ្ញាធរអប្សរា សងប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល**

ក្នុងករណីនេះ អាជ្ញាធរអប្សរា បានផ្តល់ប្រាក់ឈ្នួលនៃថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ជូនកម្មករនិយោជិតជាប់លាប់។ ប៉ុន្តែ កម្មករនិយោជិតដែលធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ ដែលអាជ្ញាធរអប្សរាចាត់ទុកថាជាកម្មករនិយោជិតម្តងម្កាល មិនជាប់លាប់ គឺមិនទទួលបានប្រាក់ឈ្នួលថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់ចូលធ្វើការនៅអាជ្ញាធរអប្សរា តាំងពីឆ្នាំ២០០៥ ដូចជា លោក **ប្រេង បាន** ចូលធ្វើការ នៅចុងឆ្នាំ២០០៥ និងត្រូវបានបញ្ឈប់ពីការងារនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ហើយលោក **យ៉ាន មុល** និង លោកស្រី **ញិប សុគុំ** ក៏ត្រូវបានបញ្ឈប់នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាដូចខាងក្រោមៈ

(១)តើការទាមទាររបស់កម្មករនិយោជិតស្ថិតក្នុងអាជ្ញាយុកាលនៃបណ្តឹងដែរ ឬទេ?

(២)តើកម្មករនិយោជិតដែលធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ អាចទាមទារឱ្យអាជ្ញាធរអប្សរាសងរំលឹកឡើងវិញនូវប្រាក់ឈ្នួលថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ដែលមិនបានផ្តល់ជូនកន្លងមក ដែរ ឬទេ?

***(១) តើការទាមទាររបស់កម្មករនិយោជិតស្ថិតក្នុងអាជ្ញាយុកាលនៃបណ្តឹងដែរ ឬទេ?***

មាត្រា ១២០ នៃច្បាប់ស្តីពីការងារចែងថាៈ *"សិទ្ធិប្តឹងសុំបើកប្រាក់ឈ្នួលត្រូវផុតរលត់ក្នុងរយៈពេលបីឆ្នាំ ក្រោយពីថ្ងៃកំណត់បើកប្រាក់ឈ្នួល។*

*គណនេយ្យដែលស្ថិតនៅក្រោមការផុតរលត់សិទ្ធិនេះរួមមាន : ប្រាក់ឈ្នួលសុទ្ធសាធ ប្រាក់បន្ទាប់បន្សំនៃប្រាក់ឈ្នួល និងគណនេយ្យទាំងអស់របស់កម្មករនិយោជិត ដែលមានប្រភពចេញពីកិច្ចសន្យាការងារ ព្រមទាំងប្រាក់បំណាច់ ដែលត្រូវបានក្នុងករណីដេញចោលផង ។"*

យោងតាមមាត្រា ១២០ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សិទ្ធិប្តឹងសុំបើកប្រាក់ឈ្នួល ត្រូវផុតរលត់ក្នុងរយៈពេលបីឆ្នាំ ក្រោយពីថ្ងៃកំណត់បើកប្រាក់ឈ្នួល។ នៅក្នុងករណីនេះ ក្រុម

ប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលបណ្តឹងនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦ ពីភាគីកម្មករនិយោជិត។ ក្នុងករណី លោក **ប្រេង បាន** ដែលបានចូលធ្វើការនៅឆ្នាំ២០០៥ មានន័យថា អាជ្ញាយុកាលនៃការប្តឹងទាមទារឱ្យសងប្រាក់ឈ្នួលថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលនោះ មិនទាន់បានផុតរលត់ទេ ដោយហេតុថា គាត់បានអនុវត្តសិទ្ធិប្តឹងនោះ ក្នុងរយៈពេលបីឆ្នាំ ចាប់តាំងពីគាត់ចូលធ្វើការ ដោយអាជ្ញាធរអប្សរាមិនដែលផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យមានប្រាក់ឈ្នួលនេះទេ។ ចំណែកករណី លោក **យ៉ាន មុល** និង លោកស្រី **ញិប សុគុំ** ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញតែកាលបរិច្ឆេទបញ្ឈប់ពីការងារ គឺនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អាជ្ញាយុកាលនៃបណ្តឹងរបស់ពួកគាត់មិនទាន់ផុតរលត់ទេ ពីព្រោះពួកគាត់បានដាក់ពាក្យបណ្តឹងប្រាំថ្ងៃ ក្រោយពីការបញ្ឈប់។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតបានអនុវត្តសិទ្ធិប្តឹងទាមទារទៅតាមមាត្រា១២០ នៃច្បាប់ស្តីពីការងារ។

***(២) តើកម្មករនិយោជិតដែលធ្វើការយកប្រាក់ឈ្នួលប្រចាំថ្ងៃ អាចទាមទារឱ្យអាជ្ញាធរអប្សរាសងរំលឹកឡើងវិញនូវប្រាក់ឈ្នួលថ្ងៃឈប់សំរាកបុណ្យ ដែលមិនបានផ្តល់ជូនកន្លងមក ដែរ ឬទេ?***

មាត្រា ១០ នៃច្បាប់ស្តីពីការងារ *"កម្មករនិយោជិតមួងម្កាលត្រូវប្រតិបត្តិនូវវិធាន និងកាតព្វកិច្ចដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ហើយក៏មានសិទ្ធិដូចគ្នាដែរ លើកលែងតែកាលណាមានខសន្យាដោយឡែកពីនេះ។"*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការបកស្រាយមាត្រា ១០ នៃច្បាប់ស្តីពីការងារខាងលើនេះថា *"កម្មករនិយោជិតមួងម្កាល និងជាប់លាប់ ទទួលបានសិទ្ធិ និងកាតព្វកិច្ចដូចគ្នាតាមច្បាប់។ នេះមានន័យថា តាមការយល់ឃើញផ្នែកផលប្រយោជន៍ វាមិនបញ្ហាទេ ដែលកម្មករនិយោជិតត្រូវបានគេហៅថា ជាកម្មករនិយោជិតមួងម្កាល ឬ ជាប់លាប់ ពីព្រោះមាត្រា ១០ នៃច្បាប់ស្តីពីការងារ បានបញ្ជាក់យ៉ាងច្បាស់ អំពីបញ្ហានេះ។" (សូមមើលសេចក្តីបង្គាប់លេខ ៩៧/០៨-អ៊ីថឺនីធី អ៊ីភែរិល ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១០ និងលេខ ១០៨/០៩-យីងចាង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៦ )*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ដែរ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អាជ្ញាធរអប្សរាត្រូវផ្តល់សិទ្ធិ និងផលប្រយោជន៍ ឱ្យកម្មករនិយោជិតមួងម្កាល ឱ្យដូចគ្នានឹងកម្មករនិយោជិតជាប់លាប់ដែរ។

មាត្រា ១៦១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"រៀងរាល់ឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារចេញប្រកាសកំណត់ថ្ងៃបុណ្យត្រូវឈប់ដោយមានប្រាក់ឈ្នួល សំរាប់កម្មករនិយោជិតនៃសហគ្រាសទាំងអស់"*។

ប្រការ ១ នៃប្រកាសលេខ ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចែងថា *"ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស...ត្រូវអនុញ្ញាតអោយកម្មករនិយោជិតរបស់ខ្លួនបានឈប់សំរាក ដោយមានប្រាក់ឈ្នួល ក្នុងឱកាសថ្ងៃឈប់បុណ្យដែលកំណត់ជារៀងរាល់ឆ្នាំ...។"*

យោងតាមមាត្រា ១៦១ នៃច្បាប់ពីការងារ និងប្រកាសលេខ ១០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា អាជ្ញាធរអប្សរាត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតរបស់ខ្លួន បានឈប់សំរាកដោយមានប្រាក់ឈ្នួល នៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល។ នៅក្នុងករណីនេះ ភាគីទាំងពីរទទួលស្គាល់ថា កន្លងមក អាជ្ញាធរអប្សរាមិនដែលផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតឈប់សម្រាកនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលទេ ដោយសារពួកគាត់ជាកម្មករនិយោជិតម្តងម្កាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់អាជ្ញាធរអប្សរា ក្នុងការផ្តល់ការឈប់សំរាកនៅថ្ងៃបុណ្យដែលមានប្រាក់ឈ្នួល ជូនតែកម្មករនិយោជិតជាប់លាប់ ដោយមិនបានផ្តល់ឱ្យកម្មករនិយោជិតម្តងម្កាលនោះ គឺជាការអនុវត្តមិនត្រឹមត្រូវទេ ពីព្រោះមាត្រា ១០ នៃច្បាប់ស្តីពីការបានផ្តល់ឱ្យកម្មករនិយោជិតជាប់លាប់ និងកម្មករនិយោជិតម្តងម្កាល នូវសិទ្ធិ អត្ថប្រយោជន៍ និងកាតព្វកិច្ចដូចគ្នា។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អាជ្ញាធរអប្សរាមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួលជូនកម្មករនិយោជិតម្តងម្កាល ដូចកម្មករនិយោជិតជាប់លាប់ដែរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្គាប់ឱ្យអាជ្ញាធរអប្សរាសងប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ជូនលោក **ប្រេង បាន** លោក **យ៉ាន មុល** និងលោកស្រី **ញិប សុគុំ** ដែលអាជ្ញាធរអប្សរាមិនបានផ្តល់ឱ្យកន្លងមក ចាប់ពីថ្ងៃចូលធ្វើការ រហូតដល់ថ្ងៃបញ្ឈប់។

**ចំណុចវិវាទទី២: *ភាគីកម្មករនិយោជិតទាមទារឱ្យអាជ្ញាធរអប្សរា ទទួលយកលោក ប្រេង បាន លោក យ៉ាន មុល និង លោកស្រី ញិប សុគុំ ចូលធ្វើការវិញ***

ក្នុងករណីនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា អាជ្ញាធរអប្សរាបានបញ្ឈប់ពួកគាត់ពីការងារ ដោយសារមានការរើសអើងសហជីព ពីព្រោះលោក សាខុន បូរិន ដែលជាអ្នកគ្រប់គ្រង ធ្លាប់បានហៅកម្មករនិយោជិតទៅការិយាល័យ ឱ្យដកខ្លួនចេញពីសហជីព ដូចជា និយាយថា បើសិនជាកម្មករនិយោជិតចង់បានការងារនេះធ្វើតទៅទៀត កម្មករនិយោជិតត្រូវលាលែងពីសហជីព។ លោកមេធាវីតំណាងភាគីអាជ្ញាធរអប្សរា បានជំទាស់ថា អាជ្ញាធរអប្សរាមិនមានការរើសអើងសហជីពនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះដូចតទៅ:

**ករណី លោក ប្រេង បាន និង លោក យ៉ាន មុល :**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លោក **ប្រេង បាន** ជាប្រធានសហជីព លោក **យ៉ាន មុ៉ល** ជាអនុប្រធានសហជីព យោងតាមវិញ្ញាបនប័ត្រចុះបញ្ជិកា លេខ ១០៧៣ ក.ក.ប.វ/វក. ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៦។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាបន្តទៀតថា តើអាជ្ញាធរអប្សរាបានបញ្ឈប់ពួកគាត់ទាំងពីរនេះ ត្រឹមត្រូវតាមច្បាប់ស្តីពីការងារដែរ ឬទេ?

មាត្រា ២៩៣ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ។..."*

*អធិការការងារដែលបានទទួលពាក្យបណ្ដឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ ....ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រោយទទួលពាក្យបណ្តឹង ...* "។

ផ្អែកលើខ្លឹមសារនៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់ការបញ្ឈប់កម្មករនិយោជិត ដែលទទួលបានការការពារ និយោជកត្រូវមានការអនុញ្ញាតពីអធិការការងារ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ។ មានន័យថា អធិការការងារមានតួនាទីពិចារណា ស្រាវជ្រាវ និងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធ ចំពោះសំណើរបស់និយោជក ដែលសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីព *ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រោយទទួលពាក្យបណ្តឹង ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤៩/០៨ -ខេមបូ ហាន់ស៊ែ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ១)*។

មាត្រាខាងលើនេះ ក៏ត្រូវបានអនុវត្តចំពោះថ្នាក់ដឹកនាំសហជីពផងដែរ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា " *... ការការពារនេះ ត្រូវបានផ្តល់ឱ្យថ្នាក់ដឹកនាំសហជីព ០៣ រូប ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ* "។

នៅក្នុងសំណុំរឿងនេះ អាជ្ញាធរអប្សរា បានបញ្ឈប់លោក **ប្រេង បាន** និងលោក **យ៉ាន មុល** នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦។ ប៉ុន្តែ អាជ្ញាធរអប្សរា មិនបានសុំការអនុញ្ញាតពីអធិការការងារទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា អាជ្ញាធរអប្សរា មិនបានគោរពតាមមាត្រា ២៩៣ និងប្រកាសលេខ ៣០៥ ទេ នៅពេលបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំង ២ នាក់នេះ។ ដូច្នេះ ការបញ្ឈប់នេះ មិនបានធ្វើឡើងស្របតាមនីតិវិធីទេ។

ជាសរុប ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យអាជ្ញាធរអប្សរា ទទួលយកលោក **ប្រេង បាន** និង លោក **យ៉ាន មុល** ចូលធ្វើការវិញ។

**ករណី លោកស្រី ញិប សុគុំ :**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ថ្នាក់ដឹកនាំសហជីព និងសមាជិកសហជីព ត្រូវបានអាជ្ញាធរអប្សរាបញ្ឈប់ពីការងារ ក្នុងនោះមានលោកស្រី **ញិប សុគុំ** ផងដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការបញ្ឈប់លោកស្រី **ញិប សុគុំ** ពាក់ពន្ធ័នឹងការរើសអើងសហជីពដែរឬទេ?

មាត្រា ១២ នៃច្បាប់ស្តីពីការងារបានចែងថា " *..... គ្មាននិយោជកណាម្នាក់អាចយកបញ្ហាការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីសំរេចអំពី ....... ការផ្តល់...... ការផ្តាច់កិច្ចសន្យាការងារ .....* "។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា " *ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនអោយយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសំរេចក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ..... និងការបណ្តេញចេញ ....* " ។

ទាក់ទងនឹងការចោទប្រកាន់ថា និយោជកមានការរើសអើងសហជីពនោះ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីកម្មករនិយោជិត មានបន្ទុកភស្តុតាងក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១២/០៦-វីវើច ហេតុផលនៃសេចក្តី សម្រេចចំណុចវិវាទទី១, លេខ ០១/០៧-ស៊ុខព្រីម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ១៤៨/ ០៧-បាយហ៊ី ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ១៥៨/០៨- អ៊ីម និងរ៉េ ទី៤ និងលេខ ៤០/០៩-ហ្គោលហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១)* ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិនិត្យទៅលើភស្តុតាង ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង និងអំណះអំណាងរបស់ភាគីនៅក្នុងសវនាការ ដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើង ទាក់ទងនឹងការបញ្ឈប់កម្មករនិយោជិត។ *(សូមមើលសេចក្តីបង្គាប់លេខ ១២៣/០៧-អ៊ីហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ១៤៨/០៧-បាយហ៊ី, លេខ ៣០/០៨-អ៊ីហ្គាមេន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ៧១/០៩-ហាយឌិច ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១២២/០៩- វ៉ាយ វី ភី ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣)* ។

យោងតាមសារណារបស់ភាគីកម្មករនិយោជិត ក៏ដូចជាការបញ្ជាក់នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានអះអាងថា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៦ លោក សុខុម បូរិន ប្រធានផ្នែកគ្រប់គ្រង បានហៅកម្មករនិយោជិតទាំងអស់ទៅប្រជុំ ហើយប្រាប់ថា ពួកគាត់អស់ការងារធ្វើហើយ មកពីពួកគាត់ទាំងអស់គ្នាចូលសហជីព។ ប្រសិនបើពួកគាត់ចង់បានការងារនេះធ្វើតទៅទៀត ពួកគាត់ត្រូវលាលែងពីសហជីព។ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ កម្មករនិយោជិតដែលជាថ្នាក់ដឹកនាំសហជីព និងសមាជិកសហជីព ត្រូវបានអាជ្ញាធរអប្សរាបញ្ឈប់ពីការងារ ក្នុងនោះមានលោកស្រី **ញិប សុគុំ** ផង ដែរ។ ជាក់ស្តែងករណី លោក **មាន ជា** នៅពេលគាត់លាឈប់ពីលេខាធិការសហជីព គាត់ត្រូវបានអាជ្ញាធរអប្សរា ទទួលឱ្យចូលធ្វើការវិញ។

ទាក់ទងនឹងអំណះអំណាងរបស់កម្មករនិយោជិតនេះ លោកមេធាវីតំណាងអាជ្ញាធរអប្សរា មិនបានធ្វើការបង្ហាញអង្គហេតុអំណះអំណាង និងភស្តុតាង ជំទាស់ណាមួយដែលបញ្ជាក់ថា អាជ្ញាធរអប្សរាមិនរើសអើងសហជីពទេ គឺគ្រាន់តែឆ្លើយតបថា អាជ្ញាធរអប្សរាមិនបានរើសអើងសហជីពទេ។ លោកមេធាវីបានបញ្ជាក់ទៀតថា បើសិនជាអាជ្ញាធរអប្សរាមានការរើសអើងសហជីព អាជ្ញាធរអប្សរាមិនអនុញ្ញាតឱ្យមានការចុះបញ្ជីកាសហជីពទេ។ លើសពីនេះទៅទៀត លោកមេធាវីមិនបានធ្វើការជំទាស់ទៅនឹងឯកសារភស្តុតាងនានា ក៏ដូចជា សារណាសង្ខេបរបស់ភាគីកម្មករនិយោជិត ដែលបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

យល់ឃើញថា អំណះអំណាងរបស់លោកមេធាវីដែលបានបញ្ជាក់ថា អាជ្ញាធរអប្សរាមិនរើសអើងសហជីពនោះ មិនអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿជាក់បានថា ការបញ្ឈប់លោកស្រី **ញិប សុគុំ** មិនមានពាក់ពន្ធ័នឹងការរើសអើងសហជីពនោះទេ។

ដូច្នេះ តាមការអះអាងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់លោកស្រី **ញិប សុគុំ** មានការពាក់ព័ន្ធនឹងការរើសអើងសហជីព ដែលវាផ្ទុយពីមាត្រា ១២ និងមាត្រា ២៧៩ នៃច្បាប់ស្តីពីការងារ ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ចូលធ្វើការវិញ ដោយសារការបញ្ឈប់កម្មករនិយោជិតមានការរើសអើងសហជីព ដែលបំពាននឹងមាត្រា ១២ និងមាត្រា ២៧៩ នៃច្បាប់ស្តីពីការងារ ដែលហាមឃាត់និយោជក មិនឱ្យយកហេតុផលនៃការចូលជាសមាជិកសហជីព ឬការធ្វើសកម្មភាពសហជីព ដើម្បីផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតរបស់ខ្លួនឡើយ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៨/០៧-ដេ ហ្វាង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣, លេខ ១២៣/០៧-អ៊ីហ្គាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១, លេខ ០៦/០៨-ឃីង ឡែន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ និងលេខ ៨៥/០៩-ណាន់ តុង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ពីព្រោះមាត្រា ១២ និងមាត្រា ២៧៩ នៃច្បាប់ស្តីពីការងារ ហាមឃាត់អាជ្ញាធរអប្សរា មិនឱ្យយកហេតុផលនៃការចូលជាសមាជិកសហជីព ឬការធ្វើសកម្មភាពសហជីព ជាមូលដ្ឋានដើម្បីបញ្ឈប់ ឬផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតរបស់ខ្លួន ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ ឱ្យអាជ្ញាធរអប្សរាទទួលយកលោកស្រី **ញិប សុគុំ** ចូលធ្វើការវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បង្គាប់ឱ្យអាជ្ញាធរអប្សរាសងប្រាក់ឈ្នួលនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល ជូនលោក **ប្រេង បាន** លោក **យ៉ាន មុល** និងលោកស្រី ញិប សុគុំ ដែលអាជ្ញាធរអប្សរាមិនបានផ្តល់ឱ្យ កន្លងមកចាប់ពីថ្ងៃចូលធ្វើការ រហូតដល់ថ្ងៃបញ្ឈប់ពីការងារ ។

**ចំណុចវិវាទទី២ :** បង្គាប់ឱ្យអាជ្ញាធរអប្សរាទទួលយកលោក ប្រេង បាន លោក **យ៉ាន មុល** និង លោកស្រី **ញិប** សុគុំ ចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ តាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

***ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល***

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេង ទួចហ៊ុន**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈរា**

ហត្ថលេខា: ------------------------------